ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:០៤.ស.ល.ខ.

## សារលិខិត
## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
## ថ្លែងជូនជនរួមជាតិ ក្នុងឱកាសទិវាជាតិយល់ដឹងអំពីមីន លើកទី២០

ជនរួមជាតិជាទីស្រលាញ់រាប់អាន!

ថ្ងៃទី២៤ ខែកុម្ភៈ ខាងមុខនេះ ជាខួបលើកទី ២០ ទិវាជាតិយល់ដឹងអំពីមីន ដើម្បីរំលឹកប្រជាពលរដ្ឋទូទាំងព្រះរាជាណាចក្រកម្ពុជា ជាពិសេសបងប្អូនជនរួមជាតិ ដែលរស់នៅក្នុងតំបន់រងផលប៉ះពាល់ដោយសារមីន សំណល់ជាតិផ្ទុះពីសង្គ្រាម និងគ្រាប់បែកចង្កោម ឲ្យមានការប្រុងប្រយ័ត្នខ្ពស់ចំពោះគ្រោះថ្នាក់ដែលបង្កឡើងដោយសារគ្រាប់ទាំងនោះ។ គ្រាប់មីន សំណល់ជាតិផ្ទុះពីសង្គ្រាម និងគ្រាប់បែកចង្កោម ដែលជាកេរ្តិ៍ដំណែលបន្សល់ទុកពី សង្គ្រាមឥណ្ឌូចិន និងជម្លោះផ្ទៃក្នុងកម្ពុជា អស់រយៈពេលជាងបីទសវត្សរ៍ មិនត្រឹមតែបង្កសោកនាដកម្ម ដ៏ធ្ងន់ធ្ងរ ចំពោះអាយុជីវិត សុខភាព ប្រជាពលរដ្ឋរបស់យើងប៉ុណ្ណោះទេ តែថែមទាំងជាឧបសគ្គ សម្រាប់ការស្តារ និងអភិវឌ្ឍន៍ជីវភាពគ្រួសារ និងសេដ្ឋកិច្ចជាតិទៀតផង។ ដើម្បីដោះស្រាយបញ្ហា រាំងស្ទះនេះ រាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកវិស័យសកម្មភាពមីនជាគោលដៅទី១៨នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ និងបានបញ្ចូលវិស័យនេះជាធាតុមួយដ៏សំខាន់ក្នុងយុទ្ធសាស្ត្រចតុកោណរបស់ខ្លួន។ ក្រោមនយោបាយ ឈ្នះ-ឈ្នះ នៅឆ្នាំ១៩៩៨ កម្ពុជាទទួលបានសន្តិភាពពេញលេញទូទាំងប្រទេស ដែលអនុញ្ញាតឲ្យរាជរដ្ឋាភិបាលមានលទ្ធភាពគ្រប់គ្រាន់ចាត់ចែងការងារវិស័យសកម្មភាពមីន នៅគ្រប់តំបន់ដែលរងការគម្រាមកំហែងដោយសារគ្រាប់ទាំងនោះ ប្រកបដោយប្រសិទ្ធភាព។ គិតមកដល់ឆ្នាំ២០១៩ សកម្មភាពបោសសម្អាតមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាមជាលក្ខណៈមនុស្សធម៌នៅកម្ពុជាមានរយៈពេល២៧ឆ្នាំមកហើយ។ ពីឆ្នាំ ១៩៩២ ដល់ ខែធ្នូ ឆ្នាំ២០១៨ បានសម្រេចរំដោះដីមានមីនបានជាង ១.៨០២ គីឡូម៉ែត្រក្រឡា ជូនប្រជាពលរដ្ឋសម្រាប់កសាងភូមិដ្ឋាន ធ្វើស្រែចំការ កសាងហេដ្ឋារចនាសម្ព័ន្ធសាធារណៈនានា និងបានរកឃើញ និងកំទេចចោលគ្រាប់មីនប្រឆាំងមនុស្សចំនួន ១.០៦២.៦៦១ គ្រាប់ មីនប្រឆាំងរថក្រោះចំនួន ២៤.៨៣២ គ្រាប់ និងសំណល់ជាតិផ្ទុះពីសង្គ្រាម ២.៧៦៧.០២០គ្រាប់ ព្រមទាំងបានធ្វើឲ្យចំនួនជនរង

គ្រោះធ្លាក់ចុះពី ៤.៣២០នាក់ ក្នុងឆ្នាំ១៩៩៦ មកត្រឹម៥៨នាក់ ក្នុងឆ្នាំ២០១៨ កន្លងទៅ ។ ទន្ទឹមនឹងនេះ គ្រោះថ្នាក់ដោយសារមីន សំណល់ជាតិផ្ទុះពីសង្គ្រាម និងគ្រាប់បែកចង្កោម ក៏នៅតែបង្កឲ្យប្រជាពលរដ្ឋយើងធ្លាក់ខ្លួនពិការ ស្លាប់បាត់បង់ជីវិត មនុស្ស សត្វពាហនៈ និងខូចខាតទ្រព្យសម្បត្តិអស់ជាច្រើន។

ដើម្បីបន្តដោះស្រាយនូវបញ្ហាគំរាមកំហែងទាំងឡាយដែលបន្សល់ទុកដោយសារមីន សំណល់ជាតិផ្ទុះពីសង្គ្រាម និងគ្រាប់បែកចង្កោម រាជរដ្ឋាភិបាលកម្ពុជាទើបតែអនុម័តនូវផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន២០១៨-២០២៥ ក្នុងគោលបំណងបំផ្លាញចោលគ្រាប់លាក់មុខទាំងនោះ ឲ្យរួចរាល់នៅត្រឹមឆ្នាំ២០២៥ ឆ្ពោះទៅរកកម្ពុជាមួយដែលគ្មានមីនឆ្នាំ២០២៥ ។ ផ្អែកតាមលទ្ធផលពីការស្រាវជ្រាវចម្ការមីនមូលដ្ឋានបានបង្ហាញថា កម្ពុជានៅមានផ្ទៃដីសង្ស័យថាមានមីន សំណល់ជាតិផ្ទុះពីសង្គ្រាម និងគ្រាប់បែកចង្កោម ប្រមាណជាង ១៩៧០ គីឡូម៉ែត្រក្រឡាទៀត ដែលត្រូវធ្វើការបោសសម្អាតពីឆ្នាំ២០១៨ ដល់ ឆ្នាំ២០២៥ និងត្រូវការថវិកាប្រមាណ ៤០៦លានដុល្លារសហរដ្ឋអាមេរិក។

ជនរួមជាតិជាទីស្នេហា !

កិច្ចប្រតិបត្តិការបោសសម្អាតមីនតែមួយផ្នែក មិនអាចផ្តល់សុវត្ថិភាពទាំងស្រុងជូនប្រជាពលរដ្ឋបានឡើយ។ ការងារដ៏សំខាន់មួយទៀតនៃវិស័យសកម្មភាពមីន គឺការអប់រំឲ្យប្រជាពលរដ្ឋបានយល់ដឹងអំពីគ្រោះថ្នាក់ដោយសារមីន សំណល់ជាតិផ្ទុះពីសង្គ្រាម និងគ្រាប់បែកចង្កោម។

តាមរយៈការសម្របសម្រួលរបស់អាជ្ញាធរមីន រាជរដ្ឋាភិបាលបានជំរុញគាំទ្រនូវកម្មវិធី និងវិធានការជាច្រើន ដើម្បីទប់ស្កាត់និងកាត់បន្ថយចំនួនគ្រោះថ្នាក់ និងសង្គ្រោះជនរងគ្រោះនានា ដោយបានជំរុញការងារអប់រំមីនដោយផ្ទាល់នៅតាមខ្នងផ្ទះ តាមសហគមន៍ តាមរយៈកីឡា ការផ្សព្វផ្សាយទូលាយតាមវិទ្យុ ទូរទស្សន៍ ផ្ទាំងប៉ាណូ ខិត្តប័ណ្ណ និងរហូតដល់ការបញ្ចូលសារអប់រំអំពីមីនទៅក្នុងកម្មវិធីសិក្សា ព្រមទាំងការអនុវត្តន៍ច្បាប់គ្រប់គ្រងអាវុធជាតិផ្ទុះ និងវិធានការរដ្ឋបាលនានាថែមទៀត។

ក្នុងឱកាសនៃទិវាជាតិយល់ដឹងពីមីន ២៤ កុម្ភៈ លើកទី២០ នេះ ខ្ញុំសូមធ្វើការអំពាវនាវជូនដល់អាជ្ញាធរមីន អាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ កងកម្លាំងប្រដាប់អាវុធ ប្រតិបត្តិករសកម្មភាពកំចាត់មីនជាតិ អន្តរជាតិ និងដៃគូអភិវឌ្ឍន៍ ព្រមទាំងប្រជាពលរដ្ឋកម្ពុជា ដូចតទៅ៖

១/អាជ្ញាធរមីន៖ សហការជាមួយអាជ្ញាធរខេត្ត/ក្រុង បង្កើត និងពង្រីក បណ្តាញស្ម័គ្រចិត្តអប់រំយល់ដឹងពីមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាមគ្រប់ភូមិ ឃុំ ស្រុក ដែលកំពុងមានការគម្រាមកំហែងដោយសារមីន សំណល់ជាតិផ្ទុះពីសង្គ្រាម និងគ្រាប់បែកចង្កោមខ្ពស់។

២/អាជ្ញាធរដែនដី៖ ត្រូវរួមសហការលើកទឹកចិត្តដល់ប្រតិបត្តិករសកម្មភាពមីន និងអង្គការពាក់ព័ន្ធ ដើម្បីគាំទ្រ និងជំរុញការអនុវត្តន៍កម្មវិធីអប់រំមីនដល់ប្រជាពលរដ្ឋទូទៅ ពិសេសប្រជាពលរដ្ឋនៅតាមសហគមន៍ ដែលងាយរងគ្រោះថ្នាក់ឲ្យបានជ្រួតជ្រាបពីហេតុផលរងគ្រោះថ្នាក់ និងផលវិបាកនៃគ្រោះថ្នាក់ ព្រមទាំងមានវិធានការឲ្យបានតឹងរឹងចំពោះទង្វើនៃការលេង ឬកែច្នៃគ្រាប់ ដែលតែងតែបង្កឲ្យមានគ្រោះថ្នាក់ ។

៣/ ប្រតិបត្តិករជាតិ អន្តរជាតិ និងដៃគូអភិវឌ្ឍន៍៖ ចូលរួមឲ្យបានខ្លាំងក្លាថែមទៀតក្នុងការជួយកាត់បន្ថយចំនួនគ្រោះថ្នាក់ ដោយត្រូវខិតខំបន្តបង្កើនសមត្ថភាពបោសសម្អាតមីន ឆ្លើយតបទៅនឹងសំណូមពរ

សំណូមពរ ជាបន្ទាន់របស់ប្រជាពលរដ្ឋ និងអាជ្ញាធរមូលដ្ឋាន ដើម្បីបញ្ចៀសនូវគ្រោះថ្នាក់ចំពោះមុខ ដោយគួបផ្សំនឹងវិធានការបច្ចេកទេសនានា ដូចជាការដាក់សញ្ញាសម្គាល់ជាដើម ឲ្យប្រជាពលរដ្ឋបានដឹងអំពីតំបន់គ្រោះថ្នាក់។

៤/ ចំពោះបងប្អូនប្រជាពលរដ្ឋ ពិសេសកុមារា កុមារីៈ

- ត្រូវរាយការណ៍ជាបន្ទាន់ឲ្យអាណាព្យាបាល សមត្ថកិច្ចនគរបាល អាជ្ញាធរមូលដ្ឋាន ឬអង្គភាពបោសសម្អាតមីនដែលនៅជិតបំផុត ពីកន្លែងគ្រាប់មីន ឬគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ដែលបងប្អូន ក្មួយៗ បានជួប ឬប្រទះឃើញ ដោយកុំប៉ះពាល់វាជាដាច់ខាត ។
- មិនត្រូវថ្វៃ និងប្រកបរបរជាមួយនឹងគ្រឿងផ្ទុះ ហើយត្រូវសាកសួរអាជ្ញាធរ ឬអ្នកដែលដឹងច្បាស់អំពីព័ត៌មានតំបន់ដែលបងប្អូន ក្មួយៗមានបំណងប្រើប្រាស់ដី ធ្វើដំណើរឆ្លងកាត់ ឬរកអនុផលព្រៃឈើ ។
- មិនត្រូវប្រើប្រាស់គ្រឿងចក្រធុនធ្ងន់ដើម្បីចូលធ្វើការរុករានដីព្រៃ ឬដីចំការ ដែលនៅមិនទាន់បានធ្វើការបោសសម្អាតមីន សំណល់ជាតិផ្ទុះពីសង្គ្រាម និងគ្រាប់បែកចង្កោម ដែលអាចបង្កឲ្យមានគ្រោះថ្នាក់ ជាពិសេសគ្រោះថ្នាក់ដោយសារមីនតោន។

ខ្ញុំសូមឆ្លៀតឱកាសដ៏មហោឡារិកនេះ សម្ដែងនូវអំណរគុណយ៉ាងជ្រាលជ្រៅ និងស្មោះស្ម័គ្របំផុតជូនចំពោះប្រទេសជាមិត្ត ដៃគូអភិវឌ្ឍន៍ បណ្ដាអង្គការជាតិ-អន្តរជាតិ និងប្រតិបត្តិករសកម្មភាពមីនទាំងអស់ ដែលបានចូលរួមយ៉ាងសកម្មជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា ក្នុងបេសកកម្មបោសសម្អាតមីននៅព្រះរាជាណាចក្រកម្ពុជា ដើម្បីសង្គ្រោះជីវិត កាត់បន្ថយគ្រោះថ្នាក់ និងលើកកម្ពស់សុវត្ថិភាពជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជាយើងខ្ញុំ ឲ្យបានប្រសើរជាលំដាប់ រួមចំណែកស្តារ និងអភិវឌ្ឍសេដ្ឋកិច្ចជាតិឲ្យបានកាន់តែរុងរឿងថ្កុំថ្កើងចាប់ហ័សថែមទៀត។ ខ្ញុំសូមប្រសិទ្ធិពរជូនបងប្អូនប្រជាពលរដ្ឋទាំងអស់ សូមប្រកបតែនឹងពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សូមអរគុណ។

ថ្ងៃ ពុធ ៩ កើត ខែ មាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ២០១៩

នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន